**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

*Kingdom of Wonder*

**ក្រសួងទេសចរណ៍**

**លេខ** ២២០ សរណ.ទេស

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ពាក្យស្នើសុំវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ តាមរយៈប្រព័ន្ធព័ត៌មានវិទ្យាអនឡាញ

ដើម្បីចូលរួមដល់កំណែទម្រង់ថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា និងពង្រឹងគុណភាពសេវាកម្មឧស្សាហកម្មទេសចរណ៍កម្ពុជា ជាពិសេសចូលរួមកាត់បន្ថយរបាំងមិនចាំបាច់ ក្រសួងទេសចរណ៍មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សមាគមសណ្ឋាគារ និងម្ចាស់សណ្ឋាគារទាំងអស់ជ្រាបថាម្ចាស់សណ្ឋាគារអាចជ្រើសរើសជម្រើសណាមួយក្នុងចំណោមជម្រើសខាងក្រោមដើម្បីដាក់ពាក្យស្នើសុំវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ៖

--ជម្រើសទី១៖ម្ចាស់សណ្ឋាគារអាច ដាក់ពាក្យស្នើសុំវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ តាមប្រព័ន្ធព័ត៌មានវិទ្យាអនឡាញ ដោយ លោក-លោកស្រីម្ចាស់សណ្ឋាគារគ្រាន់តែ៖

ក.ចូលទៅកាន់គេហទំព័រ www.cambodiatourismrating.org

ខ.បំពេញបែបបទស្នើសុំអាជ្ញាបណ្ណដោយភ្ជាប់នូវឯកសារដែលមានការទទួលស្គាល់ស្របច្បាប់

គ.ទូទាត់ថ្លៃអាជ្ញាបណ្ណតាមប្រព័ន្ធអនឡាញ ឬតាមរយៈប្រព័ន្ធវីង (Wing)

--ជម្រើសទី២៖លោក-លោកស្រី អាចបន្តអនុវត្តនីតិវិធីស្នើសុំវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារតាមនីតិវិធីចាស់គឺការដាក់ពាក្យដោយផ្ទាល់នៅតាមមន្ទីរទេសចរណ៍រាជធានី-ខេត្ត ឬនៅលេខាធិការដ្ឋាន គ.វ.ច

ព័ត៌មានបន្ថែមសូមទាក់ទងលេខាធិការដ្ឋាន គ.វ.ច ដែលមានទីតាំងនៅទីស្តីការក្រសួងទេសចរណ៍ អាសយដ្ឋាន ដីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ៥៣ ១០ ៩៩៩ រៀងរាល់ម៉ោងធ្វើការ ។

ក្រសួងទេសចរណ៍សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់សណ្ឋាគារនឹងចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត (ដើម្បីមុខការ)
- ឯកសារ-កាលប្បវត្តិ

ដីឡូត៍លេខ ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website:www.mot.kh